# ស្តង់ដារអប្បបរមាវិញ្ញាបនបត្រមធ្យមសិក្សា (HSC)

## ព័ត៌មានសម្រាប់ឪពុកម្តាយ និងអ្នកថែទាំ

សូមគោរពឪពុកម្តាយ/អ្នកថែទាំ

ការណែនាំឱ្យមានគោលនយោបាយ ស្តង់ដារអប្បបរមាវិញ្ញាបនបត្រមធ្យមសិក្សា (HSC) ដោយអាជ្ញាធរស្តង់ដារអប់រំរដ្ឋ NSW (NSW Education Standards Authority (NESA)) មានន័យថាសិស្សក្នុងរដ្ឋ NSW ចាំបាច់ត្រូវបង្ហាញស្តង់ដារអប្បបរមាផ្នែកអក្ខរកម្ម និងលេខនព្វន្ត ដើម្បីទទួលបានសមិទ្ធផលវិញ្ញាបនបត្រមធ្យមសិក្សា (HSC) របស់ពួកគេ។

សិស្សនឹងអង្គុយធ្វើតេស្តស្តង់ដារអប្បបរមា HSC ក្នុងវិស័យទាំងបីនៃការអាន ការសរសេរ និងលេខនព្វន្ត។ ការធ្វើតេស្តតាមអនឡាញនីមួយៗមានរយៈពេល៤៥នាទី ហើយត្រូវបានរៀបចំឡើងដូចខាងក្រោម៖

- សំណួរពហុចម្លើយជ្រើសរើសសម្រាប់ការអាន
- សំណួរពហុចម្លើយជ្រើសរើសសម្រាប់លេខនព្វន្ត និង
- ការធ្វើតេស្តសម្រាប់ការសរសេរ (រហូតដល់ទៅ៥០០ពាក្យ) ផ្អែកលើការរម្លឹកជាអត្ថបទ ឬដែលអាចមើលឃើញ។

សិស្សចាំបាច់ត្រូវសម្រេចបានកម្រិតទី៣ ឬកម្រិតទី៤ នៅក្នុងវិស័យទាំងបី ដើម្បីសម្រេចបានស្តង់ដារអប្បបរមា HSC។ នេះមានន័យថា សិស្សដែលបញ្ជាក់បង្ហាញឱ្យឃើញស្តង់ដារ នោះមានជំនាញចាំបាច់ដែលអាចប្រើប្រាស់បានក្នុងជីវិតប្រចាំថ្ងៃ សម្រាប់ការងារ និងការសិក្សាបន្ថែម។

សិស្សមានឱកាសជាច្រើនជារៀងរាល់ឆ្នាំដើម្បីអង្គុយធ្វើតេស្តតាមអនឡាញទាំងនេះ ចាប់ពីថ្នាក់ទី១០ រហូតដល់ចុងថ្នាក់ទី១២។ មានអំឡុងពេលរង់ចាំរវាងការព្យាយាមធ្វើតេស្តនីមួយម្តងទៀត។

សិស្សនឹងត្រូវបានគាំទ្រដោយសាលារៀន ដើម្បីបំពេញតាមស្តង់ដារអប្បបរមា HSC។ មានតេស្តសាកល្បងនៅសាលារៀន និងការបង្ហាញបំភ្លឺសំណួរនានាតាមអនឡាញនៅលើគេហទំព័រ NESA៖ https://educationstandards.nsw.edu.au/wps/portal/nesa/11-12/hsc/hsc-minimum-standard/online-tests

សូមទាក់ទងមកសាលារៀន ប្រសិនបើអ្នកចង់បានព័ត៌មានបន្ថែម។

ប្រសិនបើអ្នកជឿជាក់ថាកូនរបស់អ្នកមានតម្រូវការបន្ថែម ហើយនឹងមានសិទ្ធិទទួលបានតម្រូវការបន្ថែមសម្រាប់ការធ្វើតេស្តស្តង់ដារអប្បបរមា HSC សូមទូរសព្ទទៅអ្នកទំនាក់ទំនងសាលារៀនដូចបង្ហាញខាងក្រោម៖

ឈ្មោះអ្នកទំនាក់ទំនងសាលារៀន

លេខទូរសព្ទអ្នកទំនាក់ទំនងសាលារៀន

ដោយសេចក្តីរាប់អាន

នាយកសាលា

ឈ្មោះសាលារៀន

### សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ដើម្បីជួយអ្នកក្នុងការទាក់ទងមកសាលារៀន សូមទូរសព្ទទៅ សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ តាមលេខ 131 450 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។ សូមប្រាប់ការីទូរសព្ទនូវលេខទូរសព្ទដែលអ្នកចង់ហៅ ពេលនោះការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ ដើម្បីជួយអ្នកក្នុងការសន្ទនា។ អ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវាកម្មនេះទេ។